# សេចក្តីថ្លែងការណ៍រួម

## សូមដោះលែង និងទម្លាក់បទចោទប្រឆាំងនឹងអ្នកសារព័ត៌មាន លោក ផន សុភាព និង លោក ភាព ភារ៉ា

**ភ្នំពេញ, ថ្ងៃទី ២៧ ខែមីនា ឆ្នាំ២០២៦** — យើងខ្ញុំជាស្ថាប័នសារព័ត៌មានក្នុងស្រុក និងអន្តរជាតិ ព្រមទាំងអង្គការសង្គមស៊ីវិល ដូចមានរាយនាមខាងក្រោម ដែលធ្វើការដើម្បីលើកកម្ពស់សេរីភាពសារព័ត៌មាន និងសេរីភាពបញ្ចេញមតិ មានការខកចិត្តយ៉ាងខ្លាំងចំពោះការផ្តន្ទាទោសដែលមិនអាចទទួលយកបាន លើអ្នកសារព័ត៌មានពីររូប គឺលោក ផន សុភាព និង លោក ភាព ភារ៉ា ឱ្យជាប់ពន្ធនាគារ ១៤ឆ្នាំ។ យើងខ្ញុំសូមអំពាវនាវឱ្យរដ្ឋាភិបាលកម្ពុជាដកពាក្យបណ្តឹង និងស្នើឱ្យតុលាការដោះលែងអ្នកសារព័ត៌មានទាំងពីររូបនេះដើម្បីឱ្យឱ្យពួកគេអាចត្រឡប់ទៅជួបជុំគ្រួសារវិញ។

នៅថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២៦ សាលាឧទ្ធរណ៍ខេត្តបាត់ដំបងបានតម្កល់សេចក្តីសម្រេចរបស់សាលាដំបូងខេត្តសៀមរាប ដែលផ្តន្ទាទោសអ្នកសារព័ត៌មានទាំងពីរនាក់ឱ្យជាប់ពន្ធនាគាររយៈពេល១៤ឆ្នាំក្រោមបទចោទ«ការប្រគល់ឱ្យរដ្ឋបរទេសនូវព័ត៌មានជាអាទិ៍ដែលអាចធ្វើឱ្យអន្តរាយការការពារជាតិ»។

ក្នុងសវនាការសាលាឧទ្ធរណ៍កាលពីថ្ងៃទី ១៣ ខែមីនា ឆ្នាំ២០២៦ អ្នកសារព័ត៌មានទាំងពីររូបបានស្នើសុំឱ្យតុលាការលុបចោលបទចោទប្រកាន់មកលើពួកគេ ដោយបញ្ជាក់ថាពួកគេមិនមានបំណងក្នុងការផ្តល់ឱ្យរដ្ឋបរទេសនូវព័ត៌មានសម្ងាត់នោះទេ។ ពួកគេបានពន្យល់ថា មុនពេលចូលទៅកាន់តំបន់ជួរមុខ ក្នុងដំណើរទៅតំបន់ព្រំដែនមុនពេលត្រូវបានចាប់ខ្លួន ពួកគេបានទទួលការអនុញ្ញាតឱ្យចូលទៅតំបន់នោះ។ ពួកគេបានបដិសេធថាមិនបានដំឡើងឧបករណ៍តាមដានទីតាំង (GPS) លើទូរសព្ទពួកគេទេ ហើយបានបញ្ជាក់ថា ការបង្ហោះលើបណ្តាញសង្គមមានគោលបំណងផ្តល់ជូនឱ្យសាធារណជនបានដឹងថា កងទ័ពកម្ពុជានៅតែមានភាពរឹងមាំ។ ពួកគេក៏បានបញ្ជាក់ផងដែរថា មិនមានបំណងផ្តល់ព័ត៌មានទៅឱ្យរដ្ឋបរទេស និងមិនបានទទួលប្រាក់ពីប្រទេសថៃឡើយ។

មេធាវីរបស់ពួកគេបានស្នើសុំឱ្យតុលាការ ប្តូរបទចោទពីមាត្រា ៤៤៥ (ការប្រគល់ឱ្យរដ្ឋបរទេសនូវព័ត៌មានជាអាទិ៍ដែលអាចធ្វើឱ្យអន្តរាយការការពារជាតិ) ទៅជាមាត្រា ៤៧៩ (ការលាតត្រដាងដោយចេតនា ឬអចេតនានូវការសម្ងាត់នៃការការពារជាតិ) ដែលមានទោសស្រាលជាង។ ទោះជាយ៉ាងណា នៅថ្ងៃទី ២៦ ខែមីនា ឆ្នាំ២០២៦ សាលាឧទ្ធរណ៍បានបដិសេធសំណើនេះ ហើយបានតម្កល់សេចក្តីសម្រេចរបស់សាលាដំបូងខេត្តសៀមរាបទុកជាបានការ។

សូមបញ្ជាក់ថានៅថ្ងៃទី ២៩ ខែកក្កដា ឆ្នាំ២០២៥ អ្នកសារព័ត៌មានទាំងពីរ បានធ្វើដំណើរទៅតំបន់ព្រំដែន ដើម្បីផ្តល់ជំនួយមនុស្សធម៌ និង រាយការណ៍អំពីស្ថានភាពនៅព្រំដែន។ រដ្ឋាភិបាលបានអះអាងថា ពួកគេបានចែករំលែករូបថតមួយដែលថតនៅប្រាសាទតាក្របី ដោយជាប់រូបគ្រាប់មីននៅផ្ទៃខាងក្រោយ ហើយក្រោយមក រូបភាពនេះត្រូវបានផ្សព្វផ្សាយយ៉ាងទូលំទូលាយដោយប្រព័ន្ធផ្សព្វផ្សាយថៃ។

នៅថ្ងៃទី ១០ ខែកញ្ញា ឆ្នាំ២០២៥ សាលាដំបូងខេត្តសៀមរាប បានបញ្ជាក់ថា អ្នកសារព័ត៌មានទាំងពីរត្រូវបានចាប់ខ្លួនក្រោមបទសង្ស័យថាបានប្រមូលព័ត៌មាន និងថតរូបនៅក្នុងតំបន់យោធាហាមឃាត់ ដែលតុលាការបានអះអាងថាប៉ះពាល់ដល់ការការពារជាតិ។

ការប្រើប្រាស់បទចោទពាក់ព័ន្ធនឹងសន្តិសុខជាតិ ដែលកំណត់និយមន័យយ៉ាងទូលំទូលាយក្នុងបរិបទនេះ បានបង្កឱ្យមានការព្រួយបារម្ភអំពីផលប៉ះពាល់ទៅលើសេរីភាពបញ្ចេញមតិ និងបានរួមចំណែកបង្កើតបរិយាកាសគំរាមកំហែងដល់សេរីភាពសារព័ត៌មាន។ វាក៏បង្កើតនូវសំណួរអំពីការកម្រិតនៃទោស និងភាពស្របគ្នាជាមួយស្តង់ដារសិទ្ធិមនុស្សអន្តរជាតិ រួមទាំងសិទ្ធិសេរីភាពបញ្ចេញមតិផងដែរ។

បទចោទដ៏ធ្ងន់ធ្ងរនេះអាចនឹងបង្កការភ័យខ្លាចបន្ថែមដល់អ្នកសារព័ត៌មាន ក្នុងការអនុវត្តការងាររបស់ពួកគេ ដើម្បីបម្រើប្រយោជន៍សាធារណៈ។

បច្ចុប្បន្ន មានអ្នកសារព័ត៌មាន ៤នាក់ ត្រូវបានចោទប្រកាន់ និងឃុំខ្លួនពាក់ព័ន្ធនឹងការរាយការណ៍របស់ពួកគេ ក្នុងនោះអ្នកសារព័ត៌មាន ២នាក់ ត្រូវបានចាប់ខ្លួននៅខែកុម្ភៈ ឆ្នាំ២០២៦។ ក្នុងចំណោមអ្នកសារព័ត៌មានដែលកំពុងជាប់ឃុំទាំងនោះ អ្នកសារព័ត៌មាន ៣នាក់ នៅខេត្តបន្ទាយមានជ័យ និង ១នាក់ នៅខេត្តឧត្តរមានជ័យ។

យើងខ្ញុំសូមអំពាវនាវឱ្យរាជរដ្ឋាភិបាលកម្ពុជា លុបចោលបទចោទប្រកាន់លើអ្នកសារព័ត៌មានទាំងអស់ដែលកំពុងត្រូវបានឃុំខ្លួន និងធានាឱ្យមានការការពារយ៉ាងពេញលេញលើសេរីភាពសារព័ត៌មាន និងសេរីភាពបញ្ចេញមតិនៅក្នុងប្រទេស។

## ស្ថាប័នដែលគាំទ្រសេចក្តីថ្លែងការណ៍នេះរួមមាន៖

1. សមាគមសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា (ខេមបូចា)
2. មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ (ស៊ីស៊ីអាយអឹម)
3. អង្គការលើកកម្ពស់ប្រព័ន្ធផ្សព្វផ្សាយ និងសារគមនាគមន៍ (CMPO)
4. អង្គការសម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស (លីកាដូ)

5. សមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា (អាដហុក)
6. មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR)
7. វិទ្យាស្ថានប្រជាធិបតេយ្យកម្ពុជា (CID)
8. ក្លឹបអ្នកសារព័ត៌មានបរទេសប្រចាំប្រទេសកម្ពុជា (OPCC)
9. សហភាពជាតិនៃអ្នកសារព័ត៌មានហ្វីលីពីន (NUJP), ប្រទេសហ្វីលីពីន
10. សម្ព័ន្ធអ្នកសារព័ត៌មានឯករាជ្យ (AJI), ប្រទេសឥណ្ឌូណេស៊ី
11. សមាគមអ្នកសារព័ត៌មានទីម័រ (AJTL),ប្រទេសទីម័រខាងកើត
12. Prachatai, ប្រទេសថៃ
13. Gerakan Media Merdeka (Geramm), ប្រទេសម៉ាឡេស៊ី
14. មជ្ឈមណ្ឌលដើម្បីសារព័ត៌មានឯករាជ្យ, ប្រទេសម៉ាឡេស៊ី
15. សហព័ន្ធអ្នកសារព័ត៌មានអន្តរជាតិ (IFJ)
16. គណៈកម្មាធិការដើម្បីការពារអ្នកសារព័ត៌មាន (CPJ)